https://kohsantepheapdaily.com.kh/article/84280.html Go MAY JAN FEB
3 captures 15
6 May 2024 - 15 Jan 2025 2024 2025 2026 About this capture



# មាន16ក្រុមហ៊ុនកំពុងរុករករ៉ែលោហ:ក្រោមដីនៅឧត្តរមានជ័យ

ចែករំលែក

11 ឆ្នាំ មុន

១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ម៉ោង ០៧:០០

ខេត្តឧត្តរមានជ័យ ៖ សកម្មភាពរបស់ក្រុមហ៊ុនខ្លះដែលកំពុងធ្វើអាជីវកម្មនិងខ្លះកំពុងស្រាវជ្រាវរុករករ៉ែគ្រប់ប្រភេទ ដោយមានអាជ្ញាប័ណ្ណស្របច្បាប់នៅក្នុងខេត្ត នាពេលសព្

ខេត្តឧត្តរមានជ័យ ៖ សកម្មភាពរបស់ក្រុមហ៊ុនខ្លះដែលកំពុងធ្វើអាជីវកម្មនិងខ្លះកំពុងស្រាវជ្រាវរុករករ៉ែគ្រប់ប្រភេទ ដោយមានអាជ្ញាប័ណ្ណស្របច្បាប់នៅក្នុងខេត្ត នាពេលសព្វថ្ងៃនេះគឺមានរហូតដល់១៦ក្រុមហ៊ុន ដែលបង្កឡើងនូវការប៉ះពាល់យ៉ាងច្រើនដល់អារម្មណ៍របស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការក្នុងខេត្ត ភ័យព្រួយខ្លាចកើតមានគ្រោះធម្មជាតិនាពេលអនាគត ។

មន្ត្រីរាជការខ្លះ និងប្រជាពលរដ្ឋក្នុងខេត្តតែងនិយាយជាពាក្យចចាមអារ៉ាមពីមួយទៅមួយនៅតាមដងផ្លូវសាធារណៈ ឬនៅតាមហាង គុយទាវ កាហ្វេ ពីអារម្មណ៍របស់ពួកគាត់មានការភ័យព្រួយនាពេលអនាគត តើកូនចៅរបស់ពួកគាត់រស់នៅបែបណា បើក្រុមហ៊ុនកើតមានយ៉ាងស្អេកស្កះ ខ្លះកំពុងធ្វើសកម្មភាពស្រាវជ្រាវរុករករ៉ែក្រោមដី និងខ្លះទៀតកំពុងធ្វើអាជីវកម្មនាពេលសព្វថ្ងៃនេះ ។ ការភ័យព្រួយជាងគេ គឺខ្លាចបង្កឱ្យមានការបាត់បង់ដល់សម្បត្តិធម្មជាតិក្នុងដី និងភ័យខ្លាចបង្កឱ្យកើតមានការបាក់ស្រុតដី និងអាចឈានទៅកើតមានការរញ្ជួយដីក៏អាចថាបានដែរ នាពេលអនាគតសម្រាប់កូនចៅ ។ ទាក់ទិននឹងហេតុការណ៍នេះកោះសន្តិភាពបានជួបលោក ភុន ឡែន ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តឱ្យដឹងថា នៅក្នុងខេត្ត ក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណកំពុងធ្វើអាជីវកម្ម និងកំពុងធ្វើការស្រាវជ្រាវរុករករ៉ែក្រោមដីមានចំនួន១៦ក្រុមហ៊ុន ។ ប៉ុន្តែទាំង១៦ក្រុមហ៊ុននេះ មិនទាន់ច្បាស់ថា ក្រុម

ហុនណាខ្លះធ្វេអាជីវកម្មផ្តលផលជូនរដ្ឋបេបណា នងក្រុមហុនខ្លះគតតេពស្រាវជ្រាវរុករក បំផ្លាញនៅឡើយទេ ។ ក្រុមហ៊ុនទាំង១៦មានឈ្មោះដូចខាងក្រោម ៖

១-ក្រុមហ៊ុន YUN KHEAN M I N E R ALS CAMBODIA Co.,Ltd កំពុងធ្វើអាជីវកម្មរ៉ែថ្មូងថ្ម ស្ថិតនៅក្នុងភូមិផ្អាវ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ មានផ្ទៃដី១៤៤គីឡូម៉ែត្រក្រឡា ។
២-ក្រុមហ៊ុន WING SRUN Co.,Ltd កំពុងធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហ: ក្នុងតំបន់ត្រពាំងទៀម ស្រុកត្រពាំងប្រាសាទ មានផ្ទៃដី២០៧គីឡូម៉ែត្រក្រឡា ។
៣-ក្រុមហ៊ុន KEP POWER SUPPLY Co.,Ltd កំពុងសិក្សាស្រាវជ្រាវរ៉ែលោហ: ក្នុងទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ មានផ្ទៃដី១៩៦គីឡូម៉ែត្រក្រឡា ។
៤-ក្រុមហ៊ុន HAN SENG COAL MINE Co.,Ltd កំពុងសិក្សាស្រាវជ្រាវរ៉ែលោហ: ក្នុងតំបន់ស្រះជ្រៃ ស្រុកត្រពាំងប្រាសាទ មានផ្ទៃដី២០២គីឡូម៉ែត្រក្រឡា ។
៥-ក្រុមហ៊ុន LIBERTY MINING INTERNATIONALកំពុងសិក្សាស្រាវជ្រាវរ៉ែលោហ: ក្នុងស្រុកចុងកាល់ និងស្រុកបន្ទាយអម្ពិល មានផ្ទៃដី៣១៩,៥គីឡូម៉ែត្រក្រឡា ។
៦-ក្រុមហ៊ុន ANGKORWAT CEMENT Limited មានអាជ្ញាប័ណ្ណកំពុងធ្វើអាជីវកម្មរ៉ែមាស ក្នុងភូមិកន្ទុយជួន ឃុំបេង ស្រុកបន្ទាយអម្ពិល មានផ្ទៃដី២គីឡូម៉ែត្រក្រឡា ។
៧-ក្រុមហ៊ុន UBE DEVELOPMENT Co.,Ltd កំពុងសិក្សាស្រាវជ្រាវរ៉ែលោហ:បន្តក្នុងតំបន់គរពាំងរនាស់ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ និងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ និងស្រុកស្រីស្នំ ខេត្តសៀមរាប មានផ្ទៃដី១៥៤គីឡូម៉ែត្រក្រឡា ។
៨-ក្រុមហ៊ុន YALONG CAMBODIA MINING Co.,Ltd កំពុងសិក្សាស្រាវជ្រាវរ៉ែលោហ:បន្ត នៅក្នុងក្រុងសំរោង និងស្រុកចុងកាល់ មានផ្ទៃដី១៤៣,៨០គីឡូម៉ែត្រក្រឡា ។
៩-ក្រុមហ៊ុន ECOERA Co.,Ltd កំពុងសិក្សាស្រាវជ្រាវរ៉ែលោហ: ក្នុងឃុំពង្រ ស្រុកចុងកាល់ មានផ្ទៃដី១៧៦គីឡូម៉ែត្រក្រឡា ។
១០-ក្រុមហ៊ុន ELEMENT RESOUR-CES Co.,Ltd ក្នុងភូមិសណ្តាន់ ស្រុកស្វាយលើ ខេត្តសៀមរាប និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ មានផ្ទៃដី៣៩៧គីឡូម៉ែត្រក្រឡា។
១១-ក្រុមហ៊ុន Cambodian Resource Xin Mining Industry Co.,Ltd កំពុងសិក្សាស្រាវជ្រាវរ៉ែថ្មូងថ្មនៅក្នុងតំបន់ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ មានផ្ទៃដី២៩៧គីឡូម៉ែត្រក្រឡា ។
១២-ក្រុមហ៊ុន Samnang Angkor Development បានផ្អាកសកម្មភាពនៅក្នុងឃុំពង្រ ស្រុកចុងកាល់ មានផ្ទៃដី៦ហិកតា ។
១៣-ក្រុមហ៊ុន Asia Thai Mining Co.,Ltd កំពុងចុះធ្វើសម្រង់ទិន្នន័យភូគព្ភសាស្រ្តនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ មានផ្ទៃដី២៦៧គីឡូម៉ែត្រក្រឡា ។

១៤-ក្រុមហ៊ុន Saraburl Coal Co.,Ltd កំពុងចុះធ្វើសម្រង់ទិន្នន័យភូគព្ភសាស្រ្តក្នុងស្រុកស្វាយលើ ខេត្តសៀមរាប និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ មានផ្ទៃដី២៦១គីឡូម៉ែត្រក្រឡា ។
១៥-ក្រុមហ៊ុន KHMER FIRST COAL MINING GROUP កំពុងសិក្សាស្រាវជ្រាវរ៉ែធ្យូងថ្មក្នុងស្រុកត្រពាំងប្រាសាទ មានផ្ទៃដី២៥០គីឡូម៉ែត្រក្រឡា ។
១៦-ក្រុមហ៊ុន HAN SENG COAL MINES Co.,Ltd ទើបទទួលបានអាជ្ញាប័ណ្ណ នាពេលថ្មីៗនេះធ្វើការស្រាវជ្រាវរុករករ៉ែថ្មកំបោរ នៅក្នុងតំបន់ភ្នំជញ្ជាំង ឃុំលំទង ស្រុកអន្លង់វែង ។

គួរកត់សម្គាល់ថា មានក្រុមហ៊ុនខ្លះយើងកំពុងស្វែងរកព័ត៌មានពិតនៅឡើយ ដែលជាក្រុម

ហ៊ុន «គិតតែពីស្រាវជ្រាវរុករក» ទោះបីដឹងថា ក្រុមហ៊ុននេះរុករកឃើញរ៉ែយកទៅធ្វើអាជីវកម្មបានផលរាប់ឆ្នាំក៏ដោយ ក៏នៅតែមានឈ្មោះ «ស្រាវជ្រាវរុករក» អត់ខ្វល់រឿងសុំច្បាប់ធ្វើអាជីវកម្មទេ ។ ក្រុមហ៊ុនខ្លះ ប្រមូលយកមាសស្ទើរអស់ ក៏នៅតែមានឈ្មោះ ស្រាវជ្រាវរុករកដែរ ។ ចំណែកនៅភ្នំអន្លង់ ខេត្តព្រះវិហារដែលជាសម្បុករ៉ែមាស កំពុងក្លាយជាតំបន់អនាធិបតេយ្យពេញបន្ទុក ។ កន្លងមក មានគេយកឈ្មោះឧកញ៉ានេះ ឧកញ៉ានោះទៅធ្វើជាខែលផងជាដំបងផង បន្លាចអ្នកភូមិឱ្យខ្លាច ។ រីឯលោកប្រធានមន្ទីរឧស្សាហកម្មរ៉ែនិងថាមពលខេត្តពេលអ្នកកាសែតទូរស័ព្ទចូលម្តងៗឆ្លើយថាអត់ដឹង...សួរពេលណា ច្រើនតែឆ្លើយថាអត់ដឹង...រួចបិទទូរស័ព្ទលែងទាក់ទងបាន ដែលធ្វើឱ្យមានការសង្ស័យថា អាចជាប់ពាក់ព័ន្ធជាមួយឈ្មួញ ។ នៅមានមន្ទីរឧស្សាហកម្មរ៉ែនិងថាមពលខេត្តច្រើនទៀត ដែលមានរ៉ែមាស និងដែលកំពុងមានឈ្មួញស្រាវជ្រាវរុករកក៏ពិបាកសុំការបំភ្លឺដែរ ។ អស់លោកប្រធានមន្ទីរខ្លះមិនចង់ឱ្យអ្នកកាសែតដឹងច្រើនពេកទេ ជាមួយតំបន់រ៉ែមាសក្នុងអាណាចក្ររបស់ខ្លួន ។

តាមការកត់សម្គាល់គឺឃើញមានតែប្រធានមន្ទីរឧស្សាហកម្ម រ៉ែនិងថាមពលខេត្តឧត្តរមានជ័យ មួយប៉ុណ្ណោះ អ្នកកាសែតអាចសុំការបំភ្លឺបាន និងអាចអស់មានចម្ងល់ ៕

## អត្ថបទផ្សេងៗទៀត

Picture

ប្រាសាទមាសលោកជំទាវ ម៉ៅ លើភ្នំទ្វារនឹងក្លាយជាតំបន់ទេសចរណ៍ដ៏ទាក់ទាញថ្មីមួយបន្ថែមទៀតក្នុង

1 ថ្ងៃ មុន

ឆ្នាំ២០២៤ CDC បានអនុម័តគម្រោងវិនិយោគចំនួន៤១៤ ដែលមានទុនវិនិយោគសរុប

1 ថ្ងៃ មុន




នារីម្នាក់ជួលផ្ទះបាន៣ថ្ងៃ ស្រាប់តែលេ.បថ្នាំងងុយដេកអស់៣បន្ទះ ផ្អើលនាំគ្នាជួយសង្គ្រោះ

2 ថ្ងៃ មុន








បុរសម្នាក់ជួបជុំគ្នាផឹកស៊ីជប់លៀងមិត្ត ភក្តិទិញម៉ូតូថ្មី ព្រឹកឡើងប្រទះឃើញយ៉ាង

1 ថ្ងៃ មុន




ពិតជាសោកស្តាយធនធានមែន! បុរសជាប្តីជាឪពុកបាត់បង់ជីវិតនៅផ្លូវ៦០ម៉ែត្រ

1 ថ្ងៃ មុន




ស្រីស្រស់ម្នាក់ត្រូវតុលាការចេញដីកាបង្គាប់ឱ្យចា.ប់ខ្លួនពីបទគំរា.ម

2 ថ្ងៃ មុន



ក្មេងទំនើ.ងកា.ប់បំផ្លាញម៉ូតូរបស់យុវជនប្រុសស្រី២នាក់ខូចខាតអស់២គ្រឿង

1 ថ្ងៃ មុន

ប្តីមកពីក្រៅមកបន្ទប់ជួល ទាន់ប្រពន្ធមានប្រុសថ្មីនៅក្នុងបន្ទប់

1 ថ្ងៃ មុន




សម្តេចតេជោបញ្ជាក់ថា ជាងពាក់កណ្តាលសតវត្សរ៍នៃដំណើរជីវិត ការលំបាកបាន

1 ថ្ងៃ មុន


## ទំនាក់ទំនងតាមរយៈ:

ទូរស័ព្ទ 023 987 118

អ៊ីម៉ែល
info@kspg.co

ផ្លូវលេខ 271 សង្កាត់បឹងទំពុន ខណ្ឌ មានជ័យ រាជធានី ភ្នំពេញ

K.S.P.M Evergrow Co., Ltd


សារព័ត៌មាន កោះ សន្តិភាព
ដឹង! លឺ! គ្រប់ព័ត៌មាន

ទាញយកកម្មវិធី កោះ:អ៊ែប

[redacted]